ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

លេខៈ ១៤៤ "ឥ១"

ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២២

-សំណុំរឿងរដ្ឋប្បវេណីលេខ ១៦២០

ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

**បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ១៥ និង ០០ នាទីរសៀល លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៦២០ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២១ ដោយមានសមាសភាព៖**

**ចៅក្រមជំនុំជម្រះ**

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

**ក្រឡាបញ្ជី**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

ដើមចោទ៖ ឈ្មោះ [redacted] ចាន់ ភេទស្រី កើតថ្ងៃទី ០៦ ខែ មីនា ឆ្នាំ១៩៧០ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ [redacted]

អ្នកតំណាងដោយអាណត្តិ៖ មេធាវី [redacted] អត្តលេខ [redacted]។

ចុងចម្លើយ៖ គ្មាន។

## I. អង្គហេតុ និងចំណុចវិវាទ

**១-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

-សុំបញ្ជាក់មរណភាពឱ្យសពប្ដីឈ្មោះ [redacted] ថៃ កើតថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ១៩៥៩ ដែលបានទទួលមរណភាពកាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០២០ វេលាម៉ោង ៧និង៤៥ នាទី នៅគេហដ្ឋាន ដោយរោគាពាធ។

**២-ការពន្យល់ត្រួសៗអំពីរឿងក្ដី៖**

នៅក្នុងរឿងនេះ ឈ្មោះ [redacted] ថៃ ភេទប្រុស កើតថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ១៩៥៩ ដែលត្រូវជាប្ដីរបស់ដើមចោទឈ្មោះ [redacted] ចាន់ បានទទួលមរណភាពកាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០២០ ដោយរោគាពាធ នៅគេហដ្ឋាន ហើយក្រុមគ្រួសាររបស់ដើមចោទតាមប្រពៃណី តែមិនបានទៅធ្វើលិខិតមរណភាពទេ។ ក្រោយមកដើមចោទបានទៅសុំឱ្យសង្កាត់បញ្ជាក់មរណភាពឱ្យសពប្ដី តែខាងសង្កាត់បានប្រាប់ថាហួសពេលសុំធ្វើសំបុត្រមរណភាពហើយ ទើបដើមចោទដាក់ពាក្យសុំឱ្យតុលាការចេញសាលក្រម បញ្ជាក់មរណភាពឱ្យសពប្ដី ដើម្បីទុកប្រើប្រាស់ទៅតាមផ្លូវច្បាប់។

**៣-អង្គហេតុដែលអះអាងដោយដើមចោទ៖**

-ឈ្មោះ [redacted] ចាន់ បានអះអាងថាៈ កាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០២០ ប្ដីរបស់ខ្លួនឈ្មោះ [redacted] ថៃ បានទទួលមរណភាព ហើយគ្រួសារខ្លួនបានធ្វើបុណ្យតាមប្រពៃណី និងរៀបចំពិធីបូជាសពដូចមានក្នុងលិខិតអនុញ្ញាតបញ្ចុះសព ឬបូជាសព លេខ ១១៣៥ កបទ/មសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២០ ចេញដោយមន្ទីរសុខាភិបាលរាជធានីភ្នំពេញ។ បន្ទាប់ពីធ្វើពិធីបូជាសពរួចរាល់ ខ្លួនមិនបានទៅធ្វើសំបុត្រមរណភាពនៅសាលាសង្កាត់ទេ។ ទើបតែពេលថ្មីៗនេះ ខ្លួនទៅសុំឱ្យខាងសង្កាត់បញ្ជាក់សំបុត្រមរណភាពឱ្យសពប្ដី តែខាងសង្កាត់បានប្រាប់ថាហួសពេលសុំធ្វើសំបុត្រមរណភាពហើយ ទើបខ្លួនដាក់ពាក្យសុំឱ្យតុលាការចេញសាលក្រម បញ្ជាក់មរណភាពឱ្យសពប្ដីខ្លួន ដើម្បីទុកប្រើប្រាស់ទៅតាមផ្លូវច្បាប់។

**៤-អង្គហេតុដែលអះអាងដោយចុងចម្លើយ៖** គ្មាន។

**៥-ចំណុចគ្មានវិវាទ៖** ដើមចោទពិតជាបានទាមទារ ដូចការអះអាងខាងលើ ប្រាកដមែន។

៦-ចំណុចវិវាទ៖ គ្មាន។

## II.ការពិនិត្យភស្តុតាង

១-ភស្តុតាងជាឯកសាររបស់ដើមចោទ៖

-សៀវភៅស្នាក់នៅលេខ ៣៧៤៦៥ ចុះថ្ងៃទី ១៧-វិច្ឆិកា-២០០៦ ចំនួន ០១ច្បាប់។ (ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៣៣៥៧៩១(០១) ឈ្មោះ [redacted] ថៃ ចំនួន ០១ច្បាប់ (ថតចម្លង)

-លិខិតអនុញ្ញាតបញ្ចុះសព ឬបូជាសព លេខ ១១៣៥ កបទ/មសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២០ ចំនួន ០១ ច្បាប់។ (ថតចម្លង)

-សំបុត្របញ្ជាក់កំណើតលេខ ២៧៦២ ចុះថ្ងៃទី០៩-ធ្នូ-២០០៤ ចំនួន ០១ច្បាប់។ (ថតចម្លង)

-សំបុត្របញ្ជាក់កំណើតលេខ ២៧៦៣ ចុះថ្ងៃទី០៩-ធ្នូ-២០០៤ ចំនួន ០១ច្បាប់។ (ថតចម្លង)

-សំបុត្របញ្ជាក់កំណើតលេខ ២៧៦៤ ចុះថ្ងៃទី០៩-ធ្នូ-២០០៤ ចំនួន ០១ច្បាប់។ (ថតចម្លង)

-សំបុត្របញ្ជាក់កំណើតលេខ ២៧៦៥ ចុះថ្ងៃទី០៩-ធ្នូ-២០០៤ ចំនួន ០១ច្បាប់។ (ថតចម្លង)

-សៀវភៅគ្រួសារលេខ ០៩០១៩៥២៥ ចុះថ្ងៃទី០២-មករា-២០០៣ ចំនួន ០១ច្បាប់។ (ថតចម្លង)

២-ភស្តុតាងជាឯកសាររបស់ចុងចម្លើយ៖ គ្មាន។

៣-ការសាកសួរសាក្សី៖ គ្មាន។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

-តាមពាក្យបណ្តឹង ចុះថ្ងៃទី១៥-ធ្នូ-២០២១ និងការអះអាងរបស់ដើមចោទឈ្មោះ [redacted] ចាន់ ឃើញថា មូលហេតុដែលសុំបញ្ជាក់មរណភាពរបស់ប្តីឈ្មោះ [redacted] ថៃ ដោយហេតុថា ប្តីរបស់ខ្លួនឈ្មោះ [redacted] ថៃ បានទទួលមរណភាព ហើយគ្រួសារខ្លួនបានធ្វើបុណ្យតាមប្រពៃណី និងរៀបចំពិធីបូជាសពដូចមានក្នុងលិខិតអនុញ្ញាតបញ្ចុះសព ឬបូជាសព លេខ ១១៣៥ កបទ/មសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២០ ចេញដោយមន្ទីរសុខាភិបាលរាជធានីភ្នំពេញ។ បន្ទាប់ពីធ្វើពិធីបូជាសពរួចរាល់ ខ្លួនមិនបានទៅធ្វើសំបុត្រមរណភាពនៅសាលាសង្កាត់ទេ។ ទើបតែពេលថ្មីៗនេះ ខ្លួនទៅសុំឱ្យខាងសង្កាត់បញ្ជាក់សំបុត្រមរណភាពឱ្យសពប្តី តែខាងសង្កាត់បានប្រាប់ថាហួសពេលសុំធ្វើសំបុត្រមរណភាពហើយ ទើបខ្លួនដាក់ពាក្យសុំឱ្យតុលាការចេញសាលក្រម បញ្ជាក់មរណភាពឱ្យសពប្តីខ្លួន ដើម្បីទុកប្រើប្រាស់ទៅតាមផ្លូវច្បាប់។ គប្បីតុលាការលើកយកមកពិចារណា។

-តាមការអះអាងរបស់ដើមចោទ និងកំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី០២-កុម្ភៈ-២០២២ ឃើញថា ដើមចោទឈ្មោះ [redacted] ចាន់ មានបំណងពិតប្រាកដ ក្នុងការសុំបញ្ជាក់មរណភាពរបស់ប្តីឈ្មោះ [redacted] ថៃ មែន។ គប្បីតុលាការលើកយកមកពិចារណា។

-តាមការអះអាងរបស់ដើមចោទ និងការពិនិត្យទៅលើភស្តុតាងជាឯកសារផ្សេងៗដែលមាននៅក្នុងសំណុំរឿង ឃើញថា ប្តីរបស់ដើមចោទ ដែលមានឈ្មោះ [redacted] ថៃ ពិតជាបានទទួលមរណភាព កាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០២០ ដោយរោគាពាធនៅគេហដ្ឋាន ប្រាកដមែន ដូចមានក្នុងលិខិតអនុញ្ញាតបញ្ចុះសព ឬបូជាសព លេខ ១១៣៥ កបទ/មសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២០ ចេញដោយមន្ទីរសុខាភិបាលរាជធានីភ្នំពេញ។

ម្យ៉ាងវិញទៀត តាមរយៈសំបុត្របញ្ជាក់កំណើតលេខ ២៧៦៤ ចុះថ្ងៃទី០៩-ធ្នូ-២០០៤ , សំបុត្រកំណើតលេខ ២៧៦៥ ចុះថ្ងៃទី០៩-ធ្នូ-២០០៤ , សៀវភៅគ្រួសារលេខ ០៩០១៩៥២៥ ចុះថ្ងៃទី០២-មករា-២០០៣ និងសៀវភៅស្នាក់នៅលេខ ៣៧៤៦៥ ចុះថ្ងៃទី១៧-វិច្ឆិកា-២០០៦ អាចបញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] ចាន់ និងសពឈ្មោះ [redacted] ថៃ ពិតជាប្តីប្រពន្ធនឹងគ្នាប្រាកដមែន។



Scanned with CamScanner

ដូច្នេះ ការប្ដឹងសុំរបស់ដើមចោទឈ្មោះ [redacted] ចាន់ គឺមានមូលហេតុត្រឹមត្រូវ និងមានភាពចាំបាច់ គប្បីតុលាការទទួលស្គាល់ការទាមទារនេះ។

-ប្រាក់ប្រដាប់ក្ដីគប្បីតុលាការសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សេចក្ដីសម្រេចបញ្ចប់**

១-**បញ្ជាក់ថា** ឈ្មោះ [redacted] ថៃ ភេទប្រុស កើតថ្ងៃទី [redacted] បានទទួលមរណភាព កាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០២០ វេលាម៉ោង ០៧:៤៥ នាទី។

២-**ឱ្យមន្ត្រីទទួលបន្ទុកអត្រានុកូលដ្ឋាន** ចុះសំបុត្របញ្ជាក់មរណភាពឱ្យឈ្មោះ [redacted] ថៃ ភេទប្រុស កើតថ្ងៃទី [redacted]។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ឈ្មោះ [redacted] ចាន់។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២២ ចំពោះមុខមេធាវីតំណាងដោយអាណត្តិដើមចោទ , ចំពោះមុខដើមចោទឈ្មោះ [redacted] ចាន់ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២២។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ សុក្រ ១០ កើត ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner